ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN


# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២


លេខ ០៨ ចេញផ្សាយថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២





**សកម្មភាពបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នាថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២**

## មាតិកា


- លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានពង្រឹងតាមរយៈការ....... ២
- ចំនួនអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលបានចូលរួម..... ៦
- បណ្ណាល័យរូបភាព ៖ សកម្មភាពបោះឆ្នោតនៅតាម................. ៨
- គ.ជ.ប អរគុណដល់អ្នកសង្កេតការណ៍បោះឆ្នោត.................... ១១
- លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ.......... ១២-១៣
- សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា...... ១៥





www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានពង្រឹងតាមរយៈការបោះឆ្នោត

ក្រោយមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ១៩៩១មក នៅព្រះរាជាណាចក្រកម្ពុជាមានការរៀបចំបោះឆ្នោតចំនួន ១០លើករួចមកហើយ ពោលគឺការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញឆ្នាំ១៩៩៣ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨-២០០៣-២០០៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០២-២០០៧-២០១២ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ២០០៦-២០១២ និងការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៩ ។ ឆ្លងតាមរយៈនៃការបោះឆ្នោតទាំងនេះហើយ បានបង្ហាញឲ្យឃើញពីការវិវឌ្ឍន៍រីកចម្រើននៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាបច្ចុប្បន្ន ។

ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២ គឺជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។ នេះគឺជាជំហានមួយបន្ថែមទៀត ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជា ។ ការរៀបចំការបោះឆ្នោតនេះ ត្រូវបានបើកទូលាយឲ្យមានការចូលរួមតាមតួនាទីពីគ្រប់ភាគីពាក់ព័ន្ធតាំងពីការចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ។ កិច្ចសហការចូលរួមត្រូវបានអនុវត្តដោយច្រើនរូបភាព ដូចជា ការចូលរួមមតិយោបល់ពីស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត ទាក់ទងនឹងបទបញ្ញត្តិ និងនីតិវិធី ការផ្សព្វផ្សាយអប់រំសាធារណជន អ្នកបោះឆ្នោត ឱ្យបានយល់ដឹងអំពីច្បាប់ បទបញ្ញត្តិ និងនីតិវិធីនៃការបោះឆ្នោត ការចូលរួមពិភាក្សាតាមរយៈកិច្ចប្រជុំប្រចាំខែនីមួយៗ (ពីរ ឬបីដងក្នុងមួយខែ) ជាមួយតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្លាស់ប្តូរមតិយោបល់ និងដោះស្រាយបញ្ហា ជាពិសេស ការបណ្តុះបណ្តាលរួមគ្នារវាងមន្ត្រីបោះឆ្នោត និងស្ថាប័នពាក់ព័ន្ធ ។ ក្នុងការពិគ្រោះយោបល់ ទោះបីមានភាគីខ្លះមានយោបល់ផ្សេងក៏ដោយ ក៏ គ.ជ.ប តែងតែយកចិត្តទុកដាក់ពិនិត្យពិចារណា និងធ្វើការសម្រេចតាមសិទ្ធិអំណាចរបស់ខ្លួន ដោយផ្អែកតាមច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន និងសភាពការណ៍ ជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច និង






សកម្មភាពតម្រង់ជួរមុខការិយាល័យបោះឆ្នោត និងបោះឆ្នោតក្នុងសង្កាត់ស្ទឹងមានជ័យ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២





ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប ថ្លែងក្នុងអង្គសន្និសីទផ្សព្វផ្សាយអំពីការងារទូទៅទាក់ទងនឹងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២

នយោបាយនៃកម្ពុជា និងបានធ្វើការបកស្រាយ និងឆ្លើយតបវិញដោយភាតរៈ។

ផ្អែកតាមប្រតិទិនការងារ ព្រមទាំងបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ដែលត្រូវបានផ្សព្វផ្សាយជាមុន ការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ នេះត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ ដែលរួមមានជំហានផ្លាស់ប្ដូរធំៗ ក្នុងការគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការសម្របសម្រួលការឃោសនាបោះឆ្នោត និងការពង្រឹងយន្តការ និងប្រសិទ្ធភាពនៃការដាក់ ទទួល និងដោះស្រាយបណ្ដឹងក្នុងការបោះឆ្នោត។

ដោយកិច្ចសហការតាមតួនាទីបានល្អ ជាទូទៅការរៀបចំការបោះឆ្នោតបានប្រព្រឹត្តទៅល្អ ប្រកបដោយប្រសិទ្ធភាព និងលទ្ធផលល្អ។





កិច្ចប្រជុំផ្សព្វផ្សាយអំពីនីតិវិធីនៃការប្ដឹងត៍វ៉ា និងដោះស្រាយបណ្ដឹងទាក់ទងនឹងការសុំចុះបញ្ជីបេក្ខជន កាលថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២

ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការពង្រឹងការផ្ដល់ជូន និងការគ្រប់គ្រងឯកសារបញ្ជាក់អត្តសញ្ញាណប្រជាពលរដ្ឋក្នុងការបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃ

ទោះបីមានការរអាក់រអួលដោយព្យុះ ភ្លៀង និងជំនន់នៅរាជធានី ខេត្តមួយចំនួនក្ដី ជាទូទៅការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ បាន






វគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោត កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២

ប្រព្រឹត្តទៅដោយរលូនល្អពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។ក្នុងនោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ជាក់ស្តែងមានរយៈពេល ៤៥ថ្ងៃ គឺពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ។ ដោយឡែកឃុំ សង្កាត់ចំនួន ៣៦៧ នៃរាជធានី ខេត្តចំនួន ១៦ ដែលរងគ្រោះដោយព្យុះ ភ្លៀង និងជំនន់ ត្រូវបាន គ.ជ.ប បន្ថែមរយៈពេល ៣ថ្ងៃទៀត ។ លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គឺចុះឈ្មោះថ្មីបាន ៩៣០.៨១៥នាក់ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតបាន ២៧០.៦០៥នាក់ និងកែតម្រូវឈ្មោះ ទិន្នន័យបាន ១៤៥.៤៩៣នាក់ ។ បញ្ជីបោះឆ្នោតឆ្នាំ២០១១ ត្រូវបាន គ.ជ.ប ផ្តល់សុពលភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដែលមានឈ្មោះអ្នកបោះឆ្នោតសរុប ៩.២០៣.៤៩៣នាក់ ក្នុងនោះមានស្រី ៤.៨៦១.៨៥៣នាក់ ត្រូវជា ៥២,៨២% និងមានការិយាល័យបោះឆ្នោតចំនួន ១៨.១០៧ការិយាល័យ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ មានគណបក្សនយោបាយចំនួន ១០ និងបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបចំនួន ១១១.០៥៦ នាក់ បានចូលរួមប្រកួតប្រជែងដើម្បីដណ្តើមយកអាសនៈចំនួន ១១.៤៥៩ ក្នុងឃុំ សង្កាត់ចំនួន ១.៦៣៣ នៅទូទាំងប្រទេស ។

ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ចាប់ពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ គណបក្សនយោបាយទាំង ១០ បានបើកយុទ្ធនាការឃោសនារបស់ខ្លួនតាមលទ្ធភាពនៅតាមឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត តាមរូបភាពទ្រង់ទ្រាយតូចធំ មានការដង្ហែក្បួនឃោសនា ការដើរចែកខិត្តប័ណ្ណតាមផ្ទះ និងទីសាធារណៈ ការប្រគំតន្ត្រីតាមទីសាធារណៈ ការចាក់បញ្ចាំងវីដេអូ ស្ពាយតាមរថយន្ត ការចងបដាតាមដើមឈើ និងតាមរបងសាធារណៈ ។

ក្រៅពីការធ្វើសកម្មភាពឃោសនានៅតាមឃុំ សង្កាត់ គណបក្សនយោបាយទាំងនេះក៏បានផ្សព្វផ្សាយគោលនយោបាយរួមរបស់គណបក្សនៅថ្នាក់ជាតិផងដែរ តាមកម្មវិធីដែលរៀបចំដោយ គ.ជ.ប និងចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុរបស់រដ្ឋ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

ដំណើរការនៃការឃោសនាបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសល្អ មិនមានបញ្ហា មិនមានអំពើហិង្សាដែលនាំឱ្យរាំងស្ទះដល់ដំណើរការនៃការឃោសនាក្នុងឃុំ សង្កាត់ណាមួយឡើយ ។

ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជាង

៦៥% បានអញ្ជើញទៅបោះឆ្នោតនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ដើម្បីជ្រើសរើសតំណាងដឹកនាំឃុំ សង្កាត់ ដោយការបោះឆ្នោតជាសម្ងាត់ ដោយសេរី និងតាមឆន្ទៈរបស់ខ្លួន ។

ជាលទ្ធផលក្នុងចំណោមគណបក្សទាំង១០ ខាងលើនេះមានគណបក្សនយោបាយចំនួន ៧ បានទទួលអាសនៈជាក្រុមប្រឹក្សាឃុំ សង្កាត់ រួមមាន ៖

១. គណបក្សប្រជាជនកម្ពុជា បានទទួលអាសនៈសរុបចំនួន ៨.២៩២ ក្នុងនោះទទួលបានជាមេឃុំ ចៅសង្កាត់ចំនួន ១.៥៩២ ជំទប់ទី១ ចំនួន ១.០៥៦ ជំទប់ទី២ ចំនួន ២៥០ ។

២. គណបក្ស សម រង្ស៊ី បានទទួលអាសនៈសរុបចំនួន ២.១៥៥ ក្នុងនោះទទួលបានជាមេឃុំ ចៅសង្កាត់ចំនួន ២២ ជំទប់ទី១ ចំនួន ៣២១ ជំទប់ទី២ ចំនួន ៩៥៥ ។

៣. គណបក្សសិទ្ធិមនុស្ស បានទទួលអាសនៈសរុបចំនួន ៨០០ ក្នុងនោះទទួលបានជាមេឃុំ ចៅសង្កាត់ចំនួន ១៨ ជំទប់ទី១ ចំនួន ២០១ ជំទប់ទី២ ចំនួន ៣០៩ ។

៤. គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលអាសនៈសរុបចំនួន ១៥១ ក្នុងនោះទទួលបានជាមេឃុំចំនួន ១ ជំទប់ទី១ ចំនួន ៣០ ជំទប់ទី២ ចំនួន ៨៦។

៥. គណបក្សនរោត្តម រណឫទ្ធិ បានទទួលអាសនៈសរុបចំនួន ៥២ ក្នុងនោះទទួលបានជាជំទប់ទី១ ចំនួន ៥ ជំទប់ទី២ ចំនួន២៤ ។

៦. គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបានទទួលអាសនៈសរុបចំនួន ៨ ក្នុងនោះទទួលបានជាជំទប់ទី២ ចំនួន៨ ។

៧. គណបក្សសញ្ជាតិកម្ពុជា បានទទួលអាសនៈសរុបចំនួន ១ ក្នុងនោះទទួលបានជាជំទប់ទី២ ចំនួន១។

ដំណើរការបោះឆ្នោតនេះ ស្ថិតក្រោមការឃ្លាំមើលរបស់ភ្នាក់ងារនៃគណបក្សនយោបាយចំនួន ១១៨.៨១០ នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិចំនួន ១៤.៨៨៦នាក់ ភ្ញៀវពិសេសសង្កេតការណ៍បោះឆ្នោតចំនួន ២២នាក់ និងអ្នកសារព័ត៌មានជាតិអន្តរជាតិចំនួន ៥១២នាក់។ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បានបង្ហាញនូវការរីកចម្រើនថ្មីទៀតរបស់ខ្លួន ទាំងក្នុងការយល់ដឹង និងការអនុវត្ត គោរពក្រមសីលធម៌ រក្សាបាននូវសេចក្តីថ្លៃថ្នូរ កិច្ចសហការ និងយោគយល់គ្នា និងចេះប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនដើម្បីប្តឹងត៉ាវ ឬជំទាស់ សមស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។ ព្រមជាមួយនោះ ការទទួល និងដោះស្រាយបណ្តឹងរបស់អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ ក៏បានបង្ហាញនូវរបត់រីកចម្រើនថ្មីប្រកបដោយគុណភាព ។ ការបោះឆ្នោតនេះ ត្រូវបានគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ជាច្រើនវាយតម្លៃជាវិជ្ជមានថា ប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង ។

ប្រជាជាតិកម្ពុជាទាំងមូល អាជ្ញាធរ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកយកព័ត៌មាន រួមទាំងប្រជាពលរដ្ឋ បានចូលរួមតាមតួនាទីក្នុងការបោះឆ្នោត ។ ការបោះឆ្នោតបានផ្តល់នូវការអប់រំនយោបាយដល់ប្រជាពលរដ្ឋ និងជានាការឆ្លើយតបរបស់រដ្ឋាភិបាលប្រជាធិបតេយ្យ ចំពោះឆន្ទៈរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ។ ការបោះឆ្នោតពង្រឹងនូវស្ថិរភាព និងធម្មនុញ្ញភាពនៃសហគមន៍នយោបាយកម្ពុជា ។

រហូតមកដល់ពេលនេះ ការបោះឆ្នោតគឺជាវប្បធម៌ថ្មីមួយនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ ទោះបីការរៀបចំមិនទាន់បានពេញចិត្តពីគ្រប់មជ្ឈដ្ឋានក៏ដោយ ក៏ការបោះឆ្នោតបានចូលរួមសកម្មក្នុងការកសាង និងពង្រឹងសន្តិភាព ការអភិវឌ្ឍ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ក៏ដូចជានៅក្នុងតំបន់ ៕

# ចំនួនអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលបានចូលរួមសង្កេតមើល ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

ដើម្បីជានាឲ្យការបោះឆ្នោតបានប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានផ្តល់នូវកិច្ចសហការល្អ និងការលើកទឹកចិត្តឲ្យមានការចូលរួមសហការតាមតួនាទីពីបណ្តាប្រជាពលរដ្ឋ និងស្ថាប័នពាក់ព័ន្ធនានា ជាពិសេស ពីសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងប្រទេសនានា និងគណបក្សនយោបាយទាំងអស់ ដើម្បីពិនិត្យសង្កេតមើលដំណើរនៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ ។





ក្រុមអ្នកសង្កេតការណ៍សង្កេតមើលដំណើរការបោះឆ្នោតនាពេលកន្លងមក

ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិសរុបចំនួន **១៤.៨៨៦**នាក់ មកពីអង្គការសមាគមចំនួន **៤០** ភ្ញៀវពិសេសសង្កេតការណ៍បោះឆ្នោតចំនួន **២២**នាក់ មកពីសហគមន៍អឺរ៉ុប សហព័ន្ធអាល្លឺម៉ង់ និងស្ថានទូតបារាំង និងអ្នកសារព័ត៌មានជាតិ អន្តរជាតិសរុបចំនួន **៥១២**នាក់ មកពីអង្គភាពចំនួន **៥៣** ដើម្បីចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ។

ចំនួនអ្នកសង្កេតការណ៍ខាងលើដែល គ.ជ.ប បានទទួលស្គាល់នោះ មានអ្នកសង្កេតការណ៍ជាតិចំនួន **១៤.៧៧៨**នាក់ ក្នុងនោះស្រីចំនួន **៦.០៣៨**នាក់ និងអ្នកសង្កេតការណ៍ចល័តចំនួន **៩០**នាក់ និងអ្នកសង្កេតការណ៍អន្តរជាតិចំនួន **១០៨**នាក់ ក្នុងនោះស្រីចំនួន **៤២** នាក់ ។

**អ្នកសង្កេតការណ៍ជាតិមកពីអង្គការមិនមែនរដ្ឋាភិបាល សមាគមចំនួន ២៤ រួមមាន ៖**

១. ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **២៩៤**នាក់ ក្នុងនោះស្រីចំនួន **១២៨**នាក់ និងចល័ត **៥**នាក់ ។

២. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL) បានដាក់អ្នកសង្កេតការណ៍របស់ខ្លួនសរុបចំនួន**៥.៧៦៣**នាក់ក្នុងនោះស្រីចំនួន **២.៣៣០**នាក់ និងចល័ត **១៤**នាក់។

៣. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១.៩៤៦**នាក់ ក្នុងនោះស្រីចំនួន **៨០២**នាក់ និងចល័ត **៧**នាក់ ។

៤. អង្គការលើកស្ទួយសុខុមាលភាពជនក្រីក្រ(IHPPO) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន**១៩២**នាក់

ក្នុងនោះមានស្រីចំនួន **៨៦**នាក់ និងចល័ត **៣**នាក់។

៥. អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ (IMMHO) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៣០**នាក់ ក្នុងនោះមានស្រីចំនួន **១**នាក់ និងចល័ត **៥**នាក់ ។

៦. សហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម(FADC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៤០**នាក់ ក្នុងនោះមានស្រីចំនួន **១៤**នាក់ និងចល័ត **២**នាក់ ។

៧. អង្គការស្ត្រីសំរាប់អភិវឌ្ឍន៍សិទ្ធិមនុស្សឧស្សាហកម្មកសិកម្ម(WAHIAD) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២៧**នាក់ ក្នុងនោះមានស្រីចំនួន **១២**នាក់ និងចល័ត **៣**នាក់ ។

៨. អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ(DHRAC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១.៩៨៥**នាក់ ក្នុងនោះមានស្រីចំនួន **៨៨៨**នាក់ និងចល័ត **៦**នាក់ ។

៩. អង្គការសេវាប្រជាធិបតេយ្យ(DSO) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២៥៣**នាក់ ក្នុងនោះមានស្រីចំនួន **៦៩**នាក់ និងចល័ត **៦**នាក់ ។

១០. អង្គការព្រហ្មវិហារធម៌នៃមាតា(MINV) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១២**នាក់ ក្នុងនោះមានស្រីចំនួន **៦**នាក់ និងចល័ត **២**នាក់ ។

១១. គណៈកម្មាធិការសំរបសំរួលខ្មែរកម្ពុជាក្រោម (KKKCC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២០**នាក់ ក្នុងនោះមានស្រីចំនួន **១**នាក់ ។

១២. អង្គការសហព័ន្ធនិស្សិតបញ្ញវ័ន្តប្រជាធិបតេយ្យកម្ពុជា(CDSIF) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៣.១២៩**នាក់ ក្នុងនោះមានស្រីចំនួន **១.៣៤២**នាក់ និងចល័ត **៥**នាក់ ។

១៣. អង្គការសហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (C-FHRAD) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៣០៧**នាក់ ក្នុងនោះមានស្រីចំនួន **៩៧**នាក់ និងចល័ត **៥**នាក់ ។

១៣. អង្គការអរុណរះ(ARR) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១៨**នាក់ ក្នុងនោះមានស្រីចំនួន **៩**នាក់ និងចល័ត **៣**នាក់ ។

១៥. អង្គការអភិវឌ្ឍន៍កសិករខ្មែរ(KFDA) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៤៣**នាក់ ក្នុងនោះមានស្រីចំនួន **១២**នាក់ ។

១៦. អង្គការអភិវឌ្ឍន៍អតីតយុទ្ធជនពិការ(ADVD) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១៧៤**នាក់ ក្នុងនោះមានស្រីចំនួន **៨២**នាក់ និងចល័ត **៥**នាក់។

១៧. អង្គការសហព័ន្ធសង្គមស៊ីវិលអភិវឌ្ឍន៍កម្ពុជា (CDCSF) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២៧**នាក់ ក្នុងនោះមានស្រីចំនួន **១០**នាក់ និងចល័ត **៣**នាក់ ។

១៨. សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រាស្ត្រីក្រីក្រ(COPA) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២៧៣**នាក់ ក្នុងនោះមានស្រីចំនួន **៦៧**នាក់ និងចល័ត **៥**នាក់ ។

១៩. វិទ្យាស្ថានពលរដ្ឋវិជ្ជា(ICE) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **១៥**នាក់ ក្នុងនោះមានស្រីចំនួន **១**នាក់ និងចល័ត **២**នាក់ ។

២០. គណៈកម្មាធិការសម្របសម្រួលកម្ពុជា(CCOC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **៥៧**នាក់ ក្នុងនោះមានស្រីចំនួន **១២**នាក់ និងចល័ត **៥**នាក់។

២១. វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស(IHRD) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន **២២**នាក់ ក្នុងនោះចល័តមានចំនួន **២**នាក់ ។

២២. សមាគមអភិវឌ្ឍកសិករ និងសិទ្ធិមនុស្សយុវជនខ្មែរ (KYADFHR) បានដាក់ភ្នាក់ងារសង្កេតការណ៍

តទៅទំព័រទី ១០




# សកម្មភាព
# នៅការិយាល័យបោ
# ក្នុងរាជធា



សកម្មភាពពិនិត្យបញ្ជីឈ្មោះមុនចូលបោះឆ្នោត



សកម្មភាពតម្រង់ជួរមុខការិយាល័យបោះឆ្នោត



សកម្មភាពពិនិត្យអត្តសញ្ញាណអ្នកបោះឆ្នោត



សកម្មភាពផ្តល់សន្លឹកឆ្នោតដល់អ្នកបោះឆ្នោត

# ាបោះឆ្នោត
# ាះឆ្នោតមួយចំនួន
# ានីភ្នំពេញ






សកម្មភាពបោះឆ្នោត




សកម្មភាពជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ



សកម្មភាពបើកហិបឆ្នោត និងចាក់សន្លឹកឆ្នោត



សកម្មភាពរាប់សន្លឹកឆ្នោត

**តមកពីទំព័រទី ៧ ចំនួនអ្នកសង្កេតការ...**

សរុបចំនួន ១០៦នាក់ ក្នុងនោះមានស្រីចំនួន ៣៤នាក់ និងចល័ត ២នាក់ ។

២៣. អង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា(PCC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន ៣នាក់ ក្នុងនោះមានស្រីចំនួន ៣នាក់ ។

២៤. សមាគមយុវជនកម្ពុជា (YAC) បានដាក់ភ្នាក់ងារសង្កេតការណ៍សរុបចំនួន ៤២នាក់ ក្នុងនោះមានស្រីចំនួន ១២នាក់ ។

**អ្នកសង្កេតការណ៍មកពីអង្គការអន្តរជាតិចំនួន ១៦ រួមមាន ៖**

១. វិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **១៤**នាក់ ក្នុងនោះស្រីមានចំនួន **៨**នាក់ ។

២. មូលនិធិអន្តរជាតិសំរាប់ប្រព័ន្ធបោះឆ្នោត(IFES) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **៦**នាក់ ក្នុងនោះស្រីមានចំនួន **៤**នាក់ ។

៣. វេទិកាប្រជាពលរដ្ឋស្តីពីកម្ពុជានៅជប៉ុន(PEFOC,J) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **៥**នាក់ ក្នុងនោះស្រីមានចំនួន **៤**នាក់ ។

៤. ស្ថានទូតម៉ាឡេស៊ី បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **២**នាក់ ។

៥. ស្ថានទូតមីយ៉ាន់ម៉ា បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **២**នាក់ ក្នុងនោះស្រីចំនួន **១**នាក់ ។

៦. ស្ថានទូតដាណឺម៉ាក បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **២**នាក់ ។

៧. អង្គការសេចក្តីសង្ឃឹមពិភពលោក(WHI) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន**៤**នាក់ក្នុងនោះស្រីចំនួន **២**នាក់ ។

៨. ស្ថានទូតអាមេរិក បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **៤០**នាក់ ក្នុងនោះស្រីចំនួន **១០**នាក់ ។

៩. មជ្ឈមណ្ឌលខេមរសិក្សា (CKS) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **២**នាក់ ។

១០. ស្ថានទូតចក្រភពអង់គ្លេស បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **៤**នាក់ ក្នុងនោះស្រីមានចំនួន **៣**នាក់ ។

១១. សមាគមស្រាវជ្រាវ និងអភិវឌ្ឍន៍ប្រឹម៉ុទនាយសមុទ្រ (BORDA CAMBODIA) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **១**នាក់។

១២. អង្គការមិត្តសម្រាប់កុមារកម្ពុជា (Chibodia) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **១**នាក់ ។

១៣. អង្គការកុមារអាស៊ីអាស្លេកា (EAA) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **១**នាក់ ។

១៤. អង្គការជីវិតនៅកម្ពុជា (TLC) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន **៣**នាក់ ក្នុងនោះស្រីមានចំនួន **១**នាក់ ។

១៥. ស្ថានទូតអូស្ត្រាលី បានដាក់អ្នកសង្កេតការណ៍សរុបចំនួន ១២នាក់ ក្នុងនោះស្រីមានចំនួន ៥នាក់ ។

១៦. ស្ថានទូតស៊ុយអែត បានដាក់អ្នកសង្កេតការណ៍សរុបចំនួន ៩នាក់ ក្នុងនោះស្រីមានចំនួន ៤នាក់។

**ភ្ញៀវពិសេសសង្កេតការណ៍បោះឆ្នោតមកពី ៖**

១. សហគមន៍អឺរ៉ុបមានចំនួន ១០នាក់ ក្នុងនោះស្រីមានចំនួន ៦នាក់ ។

២. សភាសហព័ន្ធអាល្លឺម៉ង់ មានចំនួន ៨នាក់ ក្នុងនោះស្រីមានចំនួន ៤នាក់ ស្ថានទូតបារាំង មានចំនួន ៤នាក់ ក្នុងនោះស្រីមានចំនួន ១នាក់ ។

ជាមួយគ្នានេះដែរ គ.ជ.ប បានចេញប័ណ្ណអ្នកសារព័ត៌មានដល់អ្នកសារព័ត៌មានជាតិសរុបចំនួន ៤១០នាក់ ក្នុងនោះស្រីចំនួន ៤៧នាក់ និងអ្នកសារព័ត៌មានអន្តរជាតិចំនួន ១០២នាក់ ក្នុងនោះស្រីមានចំនួន ២០ នាក់ ៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ ០១.១០៧/១២ គ.ជ.ប/អគ្គ/ព.ស

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២

## គ.ជ.ប អរគុណដល់អ្នកសង្កេតការណ៍បោះឆ្នោត

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០៣ ខែមិថុនា កន្លងមកនេះ ត្រូវបានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ វាយតម្លៃជាទូទៅថា ការចាត់ចែងដំណើរការបោះឆ្នោតនេះប្រព្រឹត្តទៅ ប្រកបដោយសន្តិសុខ សុវត្ថិភាពល្អ មិនមានអំពើហិង្សា ឬភាពមិនប្រក្រតីណាមួយដែលធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោតនេះទេ ។

គ.ជ.ប សូមអរគុណ និងសូមកោតសរសើរដល់អង្គការ និងអ្នកសង្កេតការណ៍ដែលបានចូលរួមតាមដានយ៉ាងយកចិត្តទុកដាក់ និងសង្កេតមើលដំណើរការបោះឆ្នោតតាំងពីដើមរហូតដល់ចប់ ដែលធ្វើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ ប្រព្រឹត្តទៅប្រកបដោយតម្លាភាព សេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

ប៉ុន្តែក៏មានអង្គការសង្កេតការណ៍ខ្លះបានលើកឡើងនូវចំណុចអវិជ្ជមាន និងភាពមិនប្រក្រតីមួយចំនួន ដែល គ.ជ.ប យល់ថា ជាការលើកឡើងគ្មានមូលដ្ឋានជាក់ស្តែង និងមិនឈរលើមូលដ្ឋានស្តង់ដាច្បាស់លាស់ឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ គ.ជ.ប នឹងធ្វើការពិចារណានូវចំណុចខ្វះខាត ហើយខិតខំធ្វើការកែលម្អនូវបញ្ហាចន្លោះប្រហោង ដើម្បីឱ្យការបោះឆ្នោតលើកក្រោយៗកាន់តែល្អប្រសើរជាងនេះទៀត ។

គ.ជ.ប ក៏សូមអរគុណផងដែរចំពោះប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលបានខិតខំធ្វើការផ្សព្វផ្សាយអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ដែលធ្វើឱ្យប្រជាពលរដ្ឋបានជ្រួតជ្រាប និងយល់ដឹងព័ត៌មានអំពីការបោះឆ្នោត ។

ទំនាក់ទំនង : 023 214 374 / 012 855 018 ; E-mail: necinfo@forum.org.kh; www.necelect.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ (តារាងសំឡេងឆ្នោត និងភាគរយតាមគណបក្ស)

| ល.រ | ឈ្មោះ រាជធានី/ខេត្ត | គណបក្ស | | | | | | | | | | | | | | | | | | | | សរុបសន្លឹកឆ្នោត | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រជាជនកម្ពុជា | | សម រង្ស៊ី | | ហ៊្វុនស៊ិនប៉ិច | | នរោត្តមរណឫទ្ធិ | | សិទ្ធិមនុស្ស | | សម្ព័ន្ធ.ប្រជា | | ស.ខ.ក.ប្រជា | | សញ្ជាតិកម្ពុជា | | ចលនា.ប្រជា | | ខ្មែរឈប់ក្រ | | បានការ | មិនបានការ | អ្នកចេញបោះឆ្នោត ស.ឆ.ក្នុងហិប | ភាគរយ | ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោត |
| | | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | សំឡេង | ភាគរយ | | | | | |
| 01 | បន្ទាយមានជ័យ | 154,803 | 67.72 | 39,257 | 17.17 | 24,262 | 10.61 | 6,480 | 2.83 | 2,378 | 1.04 | 337 | 0.15 | 193 | 0.08 | | 0.00 | | 0.00 | 896 | 0.39 | 228,606 | 4,743 | 233,349 | 50.83 | 459,046 |
| 02 | បាត់ដំបង | 263,502 | 68.84 | 80,907 | 21.14 | 20,807 | 5.44 | 5,238 | 1.37 | 7,860 | 2.05 | 4,391 | 1.15 | | 0.00 | | 0.00 | | 0.00 | 54 | 0.01 | 382,759 | 6,857 | 389,616 | 57.36 | 679,243 |
| 03 | កំពង់ចាម | 390,464 | 52.38 | 164,672 | 22.09 | 14,753 | 1.98 | 31,663 | 4.25 | 137,187 | 18.40 | 889 | 0.12 | | 0.00 | 5,689 | 0.76 | 108 | 0.01 | 64 | 0.01 | 745,489 | 14,334 | 759,823 | 61.78 | 1,229,857 |
| 04 | កំពង់ឆ្នាំង | 127,967 | 57.88 | 45,715 | 20.68 | 11,087 | 5.01 | 14,172 | 6.41 | 21,280 | 9.62 | 214 | 0.10 | 72 | 0.03 | 537 | 0.24 | | 0.00 | 56 | 0.03 | 221,100 | 4,445 | 225,545 | 72.77 | 309,958 |
| 05 | កំពង់ស្ពឺ | 200,859 | 57.13 | 63,112 | 17.95 | 9,698 | 2.76 | 15,422 | 4.39 | 59,127 | 16.82 | 2,316 | 0.66 | | 0.00 | 663 | 0.19 | | 0.00 | 371 | 0.11 | 351,568 | 6,885 | 358,453 | 72.26 | 496,055 |
| 06 | កំពង់ធំ | 134,082 | 53.91 | 64,891 | 26.09 | 23,469 | 9.44 | 13,843 | 5.57 | 10,353 | 4.16 | 386 | 0.16 | 76 | 0.03 | 1,467 | 0.59 | | 0.00 | 141 | 0.06 | 248,708 | 5,519 | 254,227 | 60.10 | 422,974 |
| 07 | កំពត | 175,553 | 63.08 | 56,993 | 20.48 | 12,133 | 4.36 | 8,895 | 3.20 | 24,429 | 8.78 | 175 | 0.06 | 59 | 0.02 | | 0.00 | | 0.00 | 60 | 0.02 | 278,297 | 6,586 | 284,883 | 66.58 | 427,849 |
| 08 | កណ្ដាល | 350,413 | 61.25 | 118,835 | 20.77 | 8,164 | 1.43 | 6,566 | 1.15 | 83,215 | 14.54 | 1,178 | 0.21 | | 0.00 | 3,629 | 0.63 | | 0.00 | 141 | 0.02 | 572,141 | 8,934 | 581,075 | 73.72 | 788,168 |
| 09 | កោះកុង | 29,836 | 74.78 | 7,536 | 18.89 | 1,511 | 3.79 | 927 | 2.32 | | 0.00 | 87 | 0.22 | | 0.00 | | 0.00 | | 0.00 | | 0.00 | 39,897 | 990 | 40,887 | 52.92 | 77,265 |
| 10 | ក្រចេះ | 73,087 | 59.61 | 31,975 | 26.08 | 6,227 | 5.08 | 4,816 | 3.93 | 6,030 | 4.92 | | 0.00 | | 0.00 | 481 | 0.39 | | 0.00 | | 0.00 | 122,616 | 2,822 | 125,438 | 63.27 | 198,262 |
| 11 | មណ្ឌលគិរី | 14,192 | 76.92 | 2,974 | 16.12 | 1,051 | 5.70 | 28 | 0.15 | 206 | 1.12 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 18,451 | 635 | 19,086 | 59.21 | 32,237 |
| 12 | ភ្នំពេញ | 348,361 | 62.94 | 167,328 | 30.23 | 6,813 | 1.23 | 4,378 | 0.79 | 26,024 | 4.70 | 92 | 0.02 | | 0.00 | 457 | 0.08 | | 0.00 | 25 | 0.00 | 553,478 | 9,208 | 562,686 | 61.28 | 918,266 |
| 13 | ព្រះវិហារ | 51,578 | 67.09 | 18,255 | 23.74 | 4,801 | 6.24 | 781 | 1.02 | 1,468 | 1.91 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 76,883 | 3,253 | 80,136 | 71.31 | 112,378 |
| 14 | ព្រៃវែង | 258,716 | 51.65 | 92,964 | 18.56 | 7,888 | 1.57 | 19,092 | 3.81 | 117,245 | 23.41 | 1,907 | 0.38 | 58 | 0.01 | 3,028 | 0.60 | | 0.00 | | 0.00 | 500,898 | 9,796 | 510,694 | 64.99 | 785,822 |
| 15 | ពោធិ៍សាត់ | 147,735 | 80.52 | 22,545 | 12.29 | 5,227 | 2.85 | 4,181 | 2.28 | 3,271 | 1.78 | 514 | 0.28 | | 0.00 | | 0.00 | | 0.00 | | 0.00 | 183,473 | 3,168 | 186,641 | 69.78 | 267,460 |
| 16 | រតនគិរី | 34,884 | 78.31 | 6,780 | 15.22 | 2,753 | 6.18 | 131 | 0.29 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 44,548 | 1,870 | 46,418 | 59.34 | 78,221 |
| 17 | សៀមរាប | 206,384 | 60.70 | 78,950 | 23.22 | 23,632 | 6.95 | 13,618 | 4.01 | 4,035 | 1.19 | 13,274 | 3.90 | | 0.00 | 105 | 0.03 | | 0.00 | | 0.00 | 339,998 | 6,748 | 346,746 | 65.68 | 527,953 |
| 18 | ព្រះសីហនុ | 54,721 | 72.60 | 14,984 | 19.88 | 3,203 | 4.25 | 1,636 | 2.17 | 827 | 1.10 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 75,371 | 2,278 | 77,649 | 64.44 | 120,495 |
| 19 | ស្ទឹងត្រែង | 31,860 | 73.81 | 7,517 | 17.42 | 2,377 | 5.51 | 1,408 | 3.26 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 43,162 | 1,245 | 44,407 | 69.55 | 63,852 |
| 20 | ស្វាយរៀង | 188,798 | 71.61 | 41,748 | 15.83 | 8,667 | 3.29 | 5,998 | 2.27 | 18,071 | 6.85 | | 0.00 | | 0.00 | 238 | 0.09 | | 0.00 | 132 | 0.05 | 263,652 | 5,730 | 269,382 | 69.76 | 386,176 |
| 21 | តាកែវ | 309,336 | 65.92 | 79,296 | 16.90 | 15,359 | 3.27 | 8,457 | 1.80 | 55,824 | 11.90 | 624 | 0.13 | 31 | 0.01 | 322 | 0.07 | | 0.00 | | 0.00 | 469,249 | 9,472 | 478,721 | 75.31 | 635,663 |
| 22 | កែប | 16,739 | 87.99 | 1,795 | 9.44 | 490 | 2.58 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 19,024 | 460 | 19,484 | 77.78 | 25,051 |
| 23 | ប៉ៃលិន | 17,185 | 73.41 | 5,157 | 22.03 | 604 | 2.58 | 463 | 1.98 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | | 0.00 | 23,409 | 437 | 23,846 | 61.55 | 38,743 |
| 24 | ឧត្ដរមានជ័យ | 50,027 | 68.58 | 10,274 | 14.09 | 7,687 | 10.54 | 2,769 | 3.80 | 1,653 | 2.27 | 532 | 0.73 | | 0.00 | | 0.00 | | 0.00 | | 0.00 | 72,942 | 1,858 | 74,800 | 61.06 | 122,499 |
| | សរុប | 3,631,082 | 61.80 | 1,224,460 | 20.84 | 222,663 | 3.79 | 170,962 | 2.91 | 580,483 | 9.88 | 26,916 | 0.46 | 489 | 0.01 | 16,616 | 0.28 | 108 | 0.00 | 1,940 | 0.03 | 5,875,719 | 118,273 | 5,993,992 | 65.13 | 9,203,493 |

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០១២ អាណត្តិទី៣

| ល.រ | រាជធានី/ខេត្ត | គណបក្សនយោបាយដែលទទួលបានអាសនៈ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រជាជនកម្ពុជា | | | | | | សម រង្ស៊ី | | | | | | ហ៊្វុនស៊ិនប៉ិច | | | | | | នរោត្តម រណឫទ្ធិ | | | | | សិទ្ធិមនុស្ស | | | | | | សម្ព័ន្ធ ប្រជាធិប | | | សញ្ជាតិកម្ពុជា | | |
| | | សំលេង | ចំនួនអាសនៈ: សរុប | ស្ត្រី | មេឃុំ | ជំទប់ទី១ | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ស្ត្រី | មេឃុំ | ជំទប់ទី១ | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ស្ត្រី | មេឃុំ | ជំទប់ទី១ | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ស្ត្រី | ជំទប់ទី១ | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ស្ត្រី | មេឃុំ | ជំទប់ទី១ | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ជំទប់ទី២ | សំលេង | ចំនួនអាសនៈ: សរុប | ជំទប់ទី២ |
| 1 | បន្ទាយមានជ័យ | 154,803 | 405 | 85 | 64 | 46 | 8 | 39,257 | 72 | 9 | | 10 | 38 | 24,262 | 35 | 1 | 1 | 8 | 17 | 6,480 | 3 | | 1 | 2 | 2,378 | | | | | | 337 | | | | | |
| 2 | បាត់ដំបង | 263,502 | 641 | 152 | 102 | 91 | 13 | 80,907 | 160 | 26 | | 8 | 80 | 20,807 | 10 | | | 3 | 6 | 5,238 | | | | | 7,860 | 3 | | | | 3 | 4,391 | | | | | |
| 3 | កំពង់ចាម | 390,464 | 812 | 152 | 161 | 47 | 10 | 164,672 | 294 | 30 | 5 | 66 | 90 | 14,753 | 4 | | | | 3 | 31,663 | 12 | 1 | | 5 | 137,187 | 231 | 2 | 7 | 60 | 65 | 889 | | | 5,689 | | |
| 4 | កំពង់ឆ្នាំង | 127,967 | 300 | 57 | 68 | 45 | 2 | 45,715 | 87 | 13 | 1 | 15 | 48 | 11,087 | 4 | | | 3 | 1 | 14,172 | 7 | 1 | 2 | 3 | 21,280 | 21 | 3 | | 4 | 15 | 214 | | | 537 | | |
| 5 | កំពង់ស្ពឺ | 200,859 | 410 | 72 | 86 | 25 | 1 | 63,112 | 100 | 6 | 1 | 32 | 43 | 9,698 | | | | | | 15,422 | 5 | 1 | | 1 | 59,127 | 94 | | | 30 | 42 | 2,316 | | | 663 | | |
| 6 | កំពង់ធំ | 134,082 | 363 | 82 | 79 | 44 | 1 | 64,891 | 158 | 28 | 2 | 32 | 44 | 23,469 | 36 | 1 | | 5 | 22 | 13,843 | 12 | | | 7 | 10,353 | 8 | 1 | | | 7 | 386 | | | 1,467 | | |
| 7 | កំពត | 175,553 | 428 | 104 | 92 | 75 | 12 | 56,993 | 101 | 4 | | 10 | 65 | 12,133 | 3 | | | | 3 | 8,895 | 1 | | | 1 | 24,429 | 28 | 1 | 1 | 8 | 12 | 175 | | | | | |
| 8 | កណ្តាល | 350,413 | 651 | 137 | 127 | 65 | 18 | 118,835 | 165 | 15 | | 44 | 54 | 8,164 | | | | | | 6,566 | | | | | 83,215 | 98 | 2 | | 18 | 54 | 1,178 | | | 3,629 | 1 | 1 |
| 9 | កោះកុង | 29,836 | 145 | 32 | 29 | 29 | 13 | 7,536 | 22 | 3 | | | 16 | 1,511 | | | | | | 927 | | | | | | | | | | | 87 | | | | | |
| 10 | ក្រចេះ | 73,087 | 203 | 52 | 46 | 39 | 2 | 31,975 | 70 | 6 | | 5 | 38 | 6,227 | 3 | | | 1 | 1 | 4,816 | 2 | | 1 | 1 | 6,030 | 4 | | | | 4 | | | | 481 | | |
| 11 | មណ្ឌលគិរី | 14,192 | 94 | 21 | 21 | 20 | 10 | 2,974 | 12 | | | 1 | 10 | 1,051 | 1 | | | | 1 | 28 | | | | | 206 | | | | | | | | | | | |
| 12 | ភ្នំពេញ | 348,361 | 570 | 150 | 96 | 91 | 6 | 167,328 | 234 | 49 | | 4 | 86 | 6,813 | | | | | | 4,378 | | | | | 26,024 | 6 | | | 1 | 4 | 92 | | | 457 | | |
| 13 | ព្រះវិហារ | 51,578 | 243 | 57 | 44 | 41 | 13 | 18,255 | 83 | 6 | 7 | 9 | 32 | 4,801 | 5 | | | 1 | 4 | 781 | | | | | 1,468 | 2 | | | | 2 | | | | | | |
| 14 | ព្រៃវែង | 258,716 | 532 | 129 | 104 | 27 | 11 | 92,964 | 151 | 9 | 2 | 33 | 58 | 7,888 | | | | | | 19,092 | 4 | | | 1 | 117,245 | 205 | 3 | 10 | 56 | 46 | 1,907 | | | 3,028 | | |
| 15 | ពោធិ៍សាត់ | 147,735 | 315 | 61 | 49 | 47 | 28 | 22,545 | 25 | 2 | | 2 | 18 | 5,227 | | | | | | 4,181 | | | | | 3,271 | 3 | | | | 3 | 514 | | | | | |
| 16 | រតនគិរី | 34,884 | 223 | 48 | 49 | 45 | 26 | 6,780 | 30 | 2 | 1 | 3 | 20 | 2,753 | 7 | 1 | | 2 | 4 | 131 | | | | | | | | | | | | | | | | |
| 17 | សៀមរាប | 206,384 | 490 | 99 | 98 | 71 | 15 | 78,950 | 147 | 13 | 2 | 24 | 62 | 23,632 | 19 | | | 5 | 12 | 13,618 | 4 | | | 3 | 4,035 | 1 | | | | 1 | 13,274 | 7 | 7 | 105 | | |
| 18 | ព្រះសីហនុ | 54,721 | 142 | 24 | 27 | 26 | 8 | 14,984 | 25 | 1 | | 1 | 17 | 3,203 | 1 | | | | 1 | 1,636 | | | | | 827 | 1 | | | | 1 | | | | | | |
| 19 | ស្ទឹងត្រែង | 31,860 | 149 | 32 | 33 | 32 | 16 | 7,517 | 19 | 2 | 1 | 1 | 14 | 2,377 | 7 | 2 | | | 4 | 1,408 | 1 | | 1 | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 188,798 | 425 | 95 | 80 | 66 | 21 | 41,748 | 63 | 6 | | 10 | 40 | 8,667 | 3 | | | | 3 | 5,998 | | | | | 18,071 | 27 | | | 4 | 16 | | | | 238 | | |
| 21 | តាកែវ | 309,336 | 555 | 88 | 100 | 50 | 7 | 79,296 | 108 | 4 | | 30 | 59 | 15,359 | 4 | | | | | 8,457 | 1 | | | | 55,824 | 68 | | | 20 | 34 | 624 | | | 322 | | |
| 22 | កែប | 16,739 | 31 | 6 | 5 | 5 | 5 | 1,795 | | | | | | 490 | | | | | | | | | | | | | | | | | | | | | | |
| 23 | ប៉ៃលិន | 17,185 | 41 | 12 | 8 | 8 | | 5,157 | 11 | 3 | | | 8 | 604 | | | | | | 463 | | | | | | | | | | | | | | | | |
| 24 | ឧត្តរមានជ័យ | 50,027 | 124 | 34 | 24 | 21 | 4 | 10,274 | 18 | | | 1 | 15 | 7,687 | 9 | | | 2 | 4 | 2,769 | | | | | 1,653 | | | | | | 532 | 1 | 1 | | | |
| | សរុបរួម | 3,631,082 | 8,292 | 1,781 | 1,592 | 1,056 | 250 | 1,224,460 | 2,155 | 237 | 22 | 341 | 955 | 222,663 | 151 | 5 | 1 | 30 | 86 | 170,962 | 52 | 3 | 5 | 24 | 580,483 | 800 | 12 | 18 | 201 | 309 | 26,916 | 8 | 8 | 16,616 | 1 | 1 |

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១២

# សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល






សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅ គខប កណ្តាល

កាលពីព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១២ គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ(គជប) មានរៀបចំពិធីសន្និបាតបូកសរុបការងារបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដើម្បីដកស្រង់បទពិសោធន៍ ចំណុចខ្លាំង និងចំណុចខ្វះខាត សំដៅធ្វើយ៉ាងណាឱ្យការបោះឆ្នោតលើកក្រោយៗកាន់តែប្រសើរថែមទៀត ។



ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប

ពិធីនេះបានប្រព្រឹត្តទៅនៅសាលប្រជុំសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ឯកឧត្តមអភិបាលរាជធានីភ្នំពេញ និងមានអ្នកចូលរួមដែលជាតំណាងកងកម្លាំងប្រដាប់អាវុធ តំណាងអភិបាលខណ្ឌ តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល ចៅសង្កាត់ ទូទាំងរាជធានី និងប្រធាន គឃ/សប ទូទាំងរាជធានី សរុបប្រមាណ ៣៥១នាក់ ។



លោក លន់ ឆេងកែ ប្រធាន គជប ភ្នំពេញ បាន មានប្រសាសន៍ថា ការរៀបចំសន្និបាតបូកសរុបការងារ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ គឺជាកត្តាចាំបាច់ដែល គជប ភ្នំពេញ ត្រូវ ស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ ការលំបាក និង សំណូមពរនានាដែលបានលើកឡើងដោយគណបក្ស នយោបាយ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ និងមន្ត្រីបោះឆ្នោតទាំងអស់ សម្រាប់ ចងក្រងជារបាយការណ៍ផ្ញើជូនទៅ គ.ជ.ប ដើម្បីពិនិត្យ និងកែលម្អ សម្រាប់ការអនុវត្តរៀបចំការបោះឆ្នោត ក្រោយៗទៀត ។ ហើយវាជាមូលដ្ឋានមួយដ៏មានសារ សំខាន់សម្រាប់ គជប ភ្នំពេញ ដើម្បីត្រៀមលក្ខណៈសម្បត្តិ ក្នុងការរៀបចំការបោះឆ្នោតក្រោយៗទៀតផងដែរ ។

នៅក្នុងពិធីនោះដែរ ឯកឧត្តម អ៊ឹម សួស្ដី ក៏បាន ធ្វើការបកស្រាយនូវចំណុចមួយចំនួនទាក់ទងនឹងការ លើកឡើងថាមានភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតរបស់ អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

សន្និបាតបូកសរុបការងារដូចគ្នានេះដែរ ត្រូវបាន ធ្វើឡើងកាលពីថ្ងៃទី២៣ ខែមិថុនា នៅគណៈកម្មការ រៀបចំការបោះឆ្នោតខេត្តកណ្ដាល (គខប) នាសាល ប្រជុំសាលាខេត្តកណ្ដាល ដែលមានអ្នកចូលរួមសរុប ប្រមាណ ៣៣១នាក់ក្នុងនោះស្រី៣៣នាក់។អង្គសន្និបាត



លោក គឹម ហុង ប្រធាន គខប កណ្ដាល

បានធ្វើការពិភាក្សារកចំណុចខ្លាំង និងចំណុចខ្សោយ ការលំបាក និងលើកជាសំណូមពរ ដើម្បីដាក់បញ្ចូល នៅក្នុងអង្គសន្និបាតថ្នាក់ជាតិ( គ.ជ.ប) ។

លោក គឹម ហុង ប្រធាន គខប ខេត្តកណ្ដាល បានមានប្រសាសន៍ថា ជាទូទៅការបោះឆ្នោតនេះ ត្រូវ បានគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះ ឆ្នោតជាតិ អន្តរជាតិ វាយតម្លៃខ្ពស់អំពីការវិវឌ្ឍន៍ល្អទាំង ការងារបច្ចេកទេស ការងារនយោបាយ និងកិច្ចសហ ប្រតិបត្តិការពីគ្រប់ស្ថាប័នជាតិប្រកបដោយប្រសិទ្ធភាព។ ដូចនេះ ដើម្បីឱ្យការបោះឆ្នោតលើកក្រោយកាន់តែល្អ ប្រសើរជាងនេះទៀត លោកបានជំរុញឱ្យអង្គសន្និបាត ទាំងមូលធ្វើការពិភាក្សា ផ្ដល់យោបល់ ឬអនុសាសន៍ លើចំណុចសំខាន់មួយចំនួនពាក់ព័ន្ធនឹង ៖ ការស្រង់ស្ថិតិ ប្រជាពលរដ្ឋប្រចាំឆ្នាំ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការលើកកម្ពស់មន្ត្រីបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបើកយុទ្ធនាការឃោសនា បោះឆ្នោត និងកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ លំដាប់ថ្នាក់ជាដើម ។

លោកបានបន្តថា អង្គសន្និបាតត្រូវរកឱ្យឃើញ នូវចំណុចខ្លាំង និងចំណុចខ្វះខាត ហើយ គខប ត្រូវ ដាក់បញ្ចូលនៅក្នុងរបាយការណ៍ ដើម្បីលើកឡើងក្នុង សន្និបាតថ្នាក់ជាតិ( គ.ជ.ប) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១២ ខាងមុខនេះ ៕



# សកម្មភាពបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នៅការិយាល័យមួយចំនួនក្នុង ខេត្តស្វាយរៀង












